**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងព័ត៌មាន**

លេខ......៣៦៨.........ព.មប្រក

ថ្ងៃច័ន្ទ ៨រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងព័ត៌មាន

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៤៩ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨២១/៩៨២ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ស្តីពីការតែងតាំងប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧១អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- បានឃើញអនុក្រឹត្យលេខ ៣៧៥ អនក្រ. តត ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

**សម្រេច**

**ប្រការ១.-**

បង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងព័ត៌មាន ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **លី វ៉ាន់ហុង** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន និងជាសមាជិកគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | **ប្រធាន** |

២. ឯកឧត្តម **ហ៊ុយ សារ៉ាវុធ** រដ្ឋលេខាធិការ អនុប្រធាន
៣. ឯកឧត្តម **រស់ ថាន់សន** អនុរដ្ឋលេខាធិការ **អនុប្រធានអចិន្ត្រៃយ៍**
៤. ឯកឧត្តម **ផុស សុវណ្ណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ សមាជិក
៥. ឯកឧត្តម **ឃឹម ឧុទ្ធី** អគ្គនាយក នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា សមាជិក
៦. លោកជំទាវ **សុខមុំ និមល** អគ្គនាយិកា នៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា សមាជិក
៧. លោកជំទាវ **ឈឹម ពៅសុភាន់ឌី** អគ្គនាយិកា នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា សមាជិក
៨. លោក **ថោ សេដ្ឋាឧត្តម** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សមាជិក
៩. លោក **ម៉ែត ពិសី** ប្រធាននាយកដ្ឋានបុគ្គលិកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សមាជិក

**ប្រការ២**.-

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងព័ត៌មាន បំពេញតួនាទីជាសេនាធិការជូនរដ្ឋមន្ត្រី និងមានភារកិច្ចដូចតទៅ ៖

- ដឹកនាំ និងសម្របសម្រួលដំណើរការទូទៅ នៃការអនុវត្តន៍ការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងព័ត៌មាន
- រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ រៀបចំផែនការសកម្មភាព សម្រាប់អនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ដែលពាក់ព័ន្ធនឹងវិស័យព័ត៌មាន និងសោតទស្សន៍
- ដឹកនាំ សម្របសម្រួល និងគាំទ្រដល់អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរ និងអង្គភាពចំណុះក្រសួងព័ត៌មាន ដើម្បីជម្រុញការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលពាក់ព័ន្ធនឹងវិស័យព័ត៌មាន និងសោតទស្សន៍
- តាមដាន ត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រ ផែនការសកម្មភាពនៃការកែទម្រង់រដ្ឋបាលសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងព័ត៌មាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តិ គោលការណ៍ណែនាំ និងដាក់ចេញវិធានការចាំបាច់នានា សម្រាប់គាំទ្រដល់កិច្ចដំណើរការកែទម្រង់រដ្ឋបាលសាធារណៈក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឱ្យប្រព្រឹត្តទៅប្រកបដោយចីរភាព មានជំនឿទុកចិត្ត និងមានប្រសិទ្ធភាពខ្ពស់ ស្របតាមគោលការណ៍ និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ
- ប្រមូលផ្តុំ ចងក្រង បណ្តុះបណ្តាល និងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ ឯកសារបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈជូនដល់មន្ត្រី បុគ្គលិកទាំងនៅថ្នាក់ក្រសួង និងមន្ទីរ អង្គភាពខ្សែបណ្តោយក្រសួងព័ត៌មាន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យព័ត៌មាន និងសោតទស្សន៍
- ធ្វើរបាយការណ៍ប្រចាំខែពីវឌ្ឍនភាព បញ្ហា និងការប្រឈមនៃការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីរាយការណ៍ជូន រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជូនគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងព័ត៌មាន មានសិទ្ធិប្រើប្រាស់មន្ត្រី និងបុគ្គលិកក្នុងក្រសួងព័ត៌មានតាមការចាំបាច់ ដើម្បីជម្រុញការងារកែទម្រង់រដ្ឋបាលសាធារណៈឱ្យមានប្រសិទ្ធភាពខ្ពស់
- បំពេញការងារតាមការណែនាំ និងការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន។

**ប្រការ៣**.-

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងព័ត៌មាន មានរបៀបរបបបំពេញការងារ ដូចខាងក្រោម៖

- ប្រជុំជាទៀងទាត់ ០១ ខែម្តង និងអាចប្រជុំតាមការចាំបាច់ ដើម្បីដឹកនាំសម្របសម្រួល ដាក់ចេញយុទ្ធសាស្រ្ត ផែនការសកម្មភាព តាមដាន ត្រួតពិនិត្យ ដោះស្រាយបញ្ហា និងការប្រឈមនានា សំដៅជម្រុញដល់ការអនុវត្តការកែទម្រង់ រដ្ឋបាលសាធារណៈក្នុងវិស័យព័ត៌មាន និងសោតទស្សន៍
- ប្រធានក្រុមការងារជាអ្នកកោះប្រជុំ និងជាអធិបតីនៃកិច្ចប្រជុំ។ ក្នុងករណី ប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិទៅឱ្យអនុប្រធាន ហើយប្រធានស្តីទី ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ឬអនុប្រធានតាមការផ្ទេរសិទ្ធិ។ ក្នុងករណីសមាជិកណាម្នាក់អវត្តមានក្នុងករណីចាំបាច់ សមាជិកនោះអាចចាត់តំណាងចូលរួមកិច្ចប្រជុំបាន
- ប្រធានក្រុមការងារអាចអញ្ជើញតំណាងសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់
- រាល់កិច្ចប្រជុំរបស់ក្រុមការងារ ត្រូវមានកំណត់ហេតុ ដែលចុះហត្ថលេខាដោយប្រធានកិច្ចប្រជុំ និងធ្វើសេចក្តីរាយការណ៍ ជូនឯកឧត្តមរដ្ឋមន្រ្តី ។

**ប្រការ៤**.-

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងព័ត៌មាន មានលេខាធិការដ្ឋានជាសេនាធិការ សម្រាប់គាំទ្រដល់កិច្ចដំណើរការ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងព័ត៌មាន។

**ប្រការ៥**.-

ខុទ្ទកាល័យ អគ្គនាយកដ្ឋានចំណុះ មន្ទីរព័ត៌មានរាជធានី-ខេត្ត អង្គភាពក្រោមឱវាទក្រសួងព័ត៌មាន និងសាមីជនដូចក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្រ្តី

**ខៀវ កាញារីទ្ធ**

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្រ្តី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ